# អ្វីដែលត្រូវ រំពឹងទុក ក្នុងអំឡុងពេលការដ្ឋានសាងសង់ផ្នែកកណ្តាល

LDWG (Lower Duwamish Waterway Group)

នៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការរៀបចំផែនការលម្អិតជាក់លាក់សម្រាប់សកម្មភាពសម្អាត។ជាទូទៅ ក្នុងអំឡុងពេលការដ្ឋានសាងសង់សម្អាត សាធារណជនអាចរំពឹងថានឹងបានឃើញឬឮនូវ៖

- **ការរៀបចំទុកដាក់គ្រឿងចក្រ និងសម្ភារៈ។** នេះរួមបញ្ចូលទាំងការដំឡើង ការរៀបចំ និងការទុកដាក់សម្ភារៈឱ្យមានរបៀបរៀបរយ មុននឹងយកទៅប្រើប្រាស់ក្នុងកិច្ចការសាងសង់។
- **គ្រឿងចក្រសាងសង់ ដែលកំពុងធ្វើប្រតិបត្តិការ បូមស្តារភក់ ឬ ដឹកជញ្ជូនសម្ភារៈនៅលើទន្លេ។** នេះរួមបញ្ចូលទាំងទូកអូស គ្រឿងចក្របូមស្តារភក់ នៅលើសាឡង់ និងសាឡង់ដែល ដឹកជញ្ជូនសម្ភារៈសម្អាត ឬ សម្ភារៈដែលមានមេរោគ ចេញចូលតំបន់ការដ្ឋាន។
- **ទូកអូសដែលកំពុងចល័តសាឡង់ផ្ទុកទៅដោយភក់ដែលមានមេរោគ កម្ទេចកម្ទីឬសម្ភារៈសម្អាត។**សាឡង់ដែលផ្ទុកទៅដោយភក់បូមស្តារ និងកម្ទេចកម្ទី នឹងដឹកជញ្ជូនភក់ទាំងនោះពីតំបន់សម្អាតទៅកាន់ទីតាំងដាក់ទំនិញចុះនៅលើច្រាំង។នៅទីតាំងនោះ ភក់ដែលបានបូមស្តារនឹងត្រូវលើកដាក់ចុះ(បញ្ជូនមកលើដី)រួចដឹកជញ្ជូនតាមទូររថភ្លើងទៅកាន់ទីលានចាក់សំរាមដែលគ្រប់គ្រងដោយបទដ្ឋានបច្ចេកទេស។ជួនកាលទូកអូសនឹងចល័តសាឡង់ដែលផ្ទុកសម្ភារៈសម្អាត ដើម្បីយកទៅដាក់នៅតាមតំបន់សម្អាតជាក់លាក់ណាមួយក្នុងផ្លូវទឹក។
- **ក្រុមការងារកំពុងធ្វើការវាស់វែង យកសំណាកនិងធ្វើការត្រួតពិនិត្យ។**មនុស្សនៅលើទូកតូចៗកំពុងសង្កេតមើលការងារវាស់វែងបាតទន្លេតាមដានគុណភាពទឹក និងប្រមូលសំណាកទឹក និងភក់។ ការងារនេះត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ថាការបូមស្តារភក់ កំពុងត្រូវបានអនុវត្តតាមការកំណត់ដើម្បីអនុលោមតាមស្តង់ដារគុណភាពទឹក និងដើម្បីបញ្ជាក់ថា ការសាងសង់បានកាយយកភក់ដែលមានមេរោគចេញ ដូចដែលបានតម្រូវ។
- **ការដ្ឋានសាងសង់នឹងប្រព្រឹត្តទៅទាំងនៅពេលថ្ងៃ និងពេលយប់។** កាលវិភាគអាចនឹងមានការផ្លាស់ប្តូរ ផ្អែកលើទឹកជោរទឹកនាច និងប្រភេទការងារដែលកំពុងអនុវត្ត។អ្នកអាចនឹងឃើញមានពន្លឺភ្លើង ដើម្បីសុវត្ថិភាពការងារក្នុងអំឡុងពេលងងឹត។
- **គ្រឿងចក្រសាងសង់និងសកម្មភាពបុកគ្រឹះនឹងបង្កឱ្យមានសំឡេងរំខានក្នុងអំឡុងពេលប្រតិបត្តិការ។**សកម្មភាពបុកគ្រឹះដើម្បីដំឡើងជញ្ជាំងបណ្តោះអាសន្នទំនងជានឹងប្រព្រឹត្តទៅនៅទីតាំងដែលមានមេរោគ នៅចន្លោះចម្ងាយ 2.2 ម៉ៃល៍ ត្រង់ច្រកចូលខាងលិច។ ជញ្ជាំងនេះនឹងជួយបង្កើតតំបន់សម្អាត "ស្ងួត" ដើម្បីឱ្យការកាយយកភក់ចេញអាចធ្វើទៅបានដោយដាច់ដោយឡែកពីលំហូរទឹកទន្លេធម្មតា។ការងារនេះ អាចនឹងមិនកំណត់ត្រឹមតែក្នុងអំឡុងរដូវកាលសាងសង់ក្នុងទឹកនោះទេ។
- **ក្រុមការងារអាចនឹងធ្វើការវាយកម្ទេចសំណង់ និងបោសសម្អាតកម្ទេចកម្ទី។**

- **ជូនកាលមានរថយន្ត ដឹកទំនិញដឹកជញ្ជូន ភក់។** ការដឹកជញ្ជូនអាចនឹងធ្វើឡើង ពីតំបន់សម្អាតជាក់លាក់ ទៅកាន់ ទីតាំងសម្រាប់ផ្ទេរសម្ភារៈដាក់លើទូររថភ្លើង (ដើម្បីដឹកបន្តទៅកាន់ ទីលានចាក់សំរាម ដែលគ្រប់គ្រងដោយបទដ្ឋានបច្ចេកទេស)។
- **កម្មករ កំពុងតាមដាន និងទប់ស្កាត់ស្រទាប់ប្រេងស្តើងៗនៅលើផ្ទៃទឹក។** របាំងពោងបណ្តែតទឹក ឬឧបករណ៍ផ្សេងទៀត នឹង ត្រូវយកមកប្រើប្រាស់ ដើម្បីទប់ស្កាត់ក្នុងករណី ដែលគេសង្កេតឃើញ មានស្រទាប់ប្រេងស្តើងៗ ចេញពីការដ្ឋានសាងសង់សម្អាត។